# កិច្ចសំភាសន៍របស់អ៊ុំស្រីឈ្មោះ មាស មុំ

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ មាស មុំ

កៈ ជាដំបូងជំរាបសួរអ៊ុំ!

ខៈ ចាស!

កៈ ចាស! អ៊ុំថ្ងៃនេះខ្ញុំមានឪកាលដើម្បីមកសំភាសន៍អ៊ុំផ្ទាល់ ហើយខ្ញុំធ្វើការស្ម័គចិត្តនៅក្នុងគំរោងរបស់ខាងសាលា BYU ហាវៃនៅខាងសហរដ្ឋអាមេរិច!

ខៈ អឺមៗ....

កៈ ហើយខាងសាលាគេមានគំរោងមួយនិងដើម្បីជួយដល់ប្រជាជនកម្ពុជា ដើម្បីធ្វើការ Record សំលេងរបស់គាត់ហើយនិងធ្វើការសួរអំពីពង្សប្រវត្តិជីវិត ជាពិសេសបទពិសោធន៍ដែលគាត់ធ្លាប់ឆ្លងកាត់កន្លងមកថាគាត់មានបទពិសោធន៍អ្វីខ្លះ ដើម្បីគេនិងយកទៅរក្សារដើម្បីអោយកូនចៅជំនាន់ក្រោយគេបានស្តាប់ណាអ៊ុំស្រី!

ខៈ អឺម....ចាសៗ!

កៈ ចាស! អញ្ចឹងថ្ងៃនេះខ្ញុំមានឪកាសដើម្បីមកសំភាសន៍អ៊ុំស្រីផ្ទាល់ តើអ៊ុំស្រីនិងអនុញ្ញាតអោយខ្ញុំធ្វើការថតសំលេងរបស់អ៊ុំស្រីនិងដើម្បីយកទៅផុសនៅក្នុង Website របស់សាលាដែរឬទេ?

ខៈ ចាស!

កៈ ចាស! អ៊ុំស្រីអនុញ្ញាតហើយហ៎?

ខៈ ចាស! អនុញ្ញាត!

កៈ ចាស! អញ្ចឹងអរគុណអ៊ុំស្រីថ្ងៃនេះគឺជាថ្ងៃទី១៤ ខែ០៧ ឆ្នាំ២០១៨! (មានសំលេងរំខានពីខាងក្រៅ)

ខៈ អឺម....

កៈ ហើយការសំភាសន៍មុនដំបូងខ្ញុំសុំសួរឈ្មោះអ៊ុំស្រី តើអ៊ុំស្រីមានឈ្មោះអ្វីដែរ?

ខៈ ខ្ញុំឈ្មោះ មាស....មាស មុំ!

កៈ ចាស! អ៊ុំ ហើយអ៊ុំស្រីមានឈ្មោះហៅក្រៅដែរឬទេ?

ខៈ គេហៅតែ អា មុំៗ!

កៈ អូ....

គៈ អត់ទៅធ្វើការទេ?

ខៈ អត់ផង!

កៈ ហើយអ៊ុំស្រីឈ្មោះនិងអ្នកណាជាអ្នកដាក់អោយអ៊ុំស្រីដែរ?

ខៈ ឈ្មោះនិងឪពុកម្ដាយជាអ្នកដាក់អោយ!

កៈ គាត់ជាអ្នកដាក់ឈ្មោះនិងអោយអ៊ុំ?

ខៈ ចាស! ចាស!

កៈ គាត់មានបានប្រាប់ថាឈ្មោះនិង.... គាត់មានប្រាប់ថាឈ្មោះនិងមានអត្ថន័យយ៉ាងមិចទេ?

ខៈ អត់ទេគាត់មើលដាក់ឈ្មោះអញ្ចឹងអោយតែម្ដង គាត់មើលដាក់ឈ្មោះអោយកូនៗគឺគ្រប់តែកូនគ្រប់អីនិងតែម្ដង ឪពុកម្ដាយយើងជាអ្នកដាក់អោយនិយាយទៅឪពុកម្ដាយគាត់ជាអ្នកដាក់អោយឈ្មោះនិងអត់មានប្រែប្រួលអីទេ!

កៈ ចាស! ចុះឪម្ដាយរបស់អ៊ុំស្រីពួកគាត់មានឈ្មោះអ្វីដែរ?

ខៈ អឺ....ឪពុកខ្ញុំគាត់មានឈ្មោះ មិញ គាត់ឈ្មោះ លុច មាឌ គាត់មានឈ្មោះ លុច មាឌ ប៉ុន្តែគាត់អត់នៅជាមួយខ្ញុំទេគាត់នៅជាមួយប្អូនស្រី!

កៈ អូ....

ខៈ ចាស!

កៈ ចាស! ចុះលោកឪពុកវិញគាត់មានឈ្មោះអ្វីដែរ?

ខ៖ ឪពុកខ្ញុំគាត់មានឈ្មោះ មាស សាភឿន គាត់បានស្លាប់ហើយ!

ក៖ គាត់ស្លាប់យូរហើយហ៎អ៊ុំស្រី?

ខ៖ គាត់ស្លាប់យូរហើយគាត់ស្លាប់ជិតដប់ឆ្នាំហើយ!

ក៖ អូ....គាត់ស្លាប់យូរដែរហើយ!

ខ៖ និងហើយគាត់ស្លាប់យូរហើយ!

ក៖ គាត់ស្លាប់ដោយសារអ្វីដែរ?

ខ៖ ចាស....?

ក៖ គាត់ស្លាប់ដោយសារអ្វីដែរអ៊ុំ?

ខ៖ ឈឺ....គាត់ឈឺចាស់និងណាអូន!

ក៖ អ៊ឹម....អ៊ុំស្រីមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានបងប្អូនប្រាំពីរនាក់!

ក៖ អ៊ុំមានបងប្អូនស្រីប៉ុន្មាននាក់ប្រុសប៉ុន្មាននាក់ដែរ?

ខ៖ បងប្អូនរបស់ខ្ញុំមានស្រីបួននាក់ហើយប្រុសបីនាក់!

ក៖ គាត់មានឈ្មោះអ្វីខ្លះដែរទៅ? (មានសំលេងរំខានពីខាងក្រៅ)

ខ៖ គាត់មានឈ្មោះអេ....បើហៅឈ្មោះក្រៅឪពុកគាត់ដាក់ត្រកូលឈ្មោះខុសៗគ្នាអញ្ចឹងទៅណាស់ គាត់មានឈ្មោះអឺ.... តឿមួយ ឈ្មោះ ស៊ីនុន ឈ្មោះ ទូច ឈ្មោះ ម៉ុង ហើយដល់ប្រុសៗឈ្មោះ លៃ ឈ្មោះ លី ឈ្មោះ ឡាត់ មានតែប៉ុននឹង!

ក៖ អញ្ចឹងសរុបទៅអ៊ុំស្រីមានប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ បងប្អូនខ្ញុំទាំងអស់មានប្រាំពីរនាក់!

ក៖ ប្រាំពីរនាក់ណោះ?

ខ៖ ចាស!

កៈ ហើយពួកគាត់រៀបការហើយអស់ឬនៅអ៊ុំស្រី?

ខៈ រៀបការរួចអស់ហើយ រៀបការហើយអស់ហើយ!

កៈ អ៊ឹម....

ខៈ ចាស!

កៈ គាត់មានមុខរបររកស៊ីអ្វីដែរ?

ខៈ ចាស! ពួកគាត់មកធ្វើការរកស៊ីអស់ហើយ!

កៈ ហើយគាត់មករកស៊ីនៅភ្នំពេញឬនៅតាមខេត្ត?

ខៈ ចាស! គាត់មករកស៊ីនៅភ្នំពេញ (មានសំលេងរំខានពីខាងក្រៅ)!

កៈ គាត់មករកស៊ីនៅភ្នំពេញទាំងអស់?

ខៈ ចាស! នៅភ្នំពេញ មករកស៊ីនៅភ្នំពេញ!

កៈ ចុះស្រុកកំណើតរបស់អ៊ុំស្រីនៅឯណាដែរ?

ខៈ ស្រុកកំណើតរបស់ខ្ញុំនៅខេត្តកំពត!

កៈ ហើយអឺ....នៅភូមិឃុំណាដែរអ៊ុំ?

ខៈ ខេត្តកំពតនៅឃុំអឺ....ទឹកអឺ....នៅភូមិបន្ទាយមាស នៅស្រុកបន្ទាយមាស ខេត្តបន្ទាយមាសអីទេ ខ្ញុំវារាងភ្លេចៗអស់ហើយ!

កៈ (សើច)

ខៈ ភ្លេចបាត់ហើយដឹងតែនៅខេត្តកំពត បន្ទាយមាសខេត្តកំពតនិងហើយ!

កៈ ចុះឥឡូវអ៊ុំស្រីអត់ដែលទៅលេងស្រុកទេហ៎?

ខៈ អត់ទេអត់សូវបានដែលទៅផងបើម៉ែឪគាត់យកមកនៅនេះ!

កៈ អ៊ឹម....ចាស ចុះអ៊ុំសព្វថ្ងៃនិងមានទីលំនៅ នៅឯណាដែរ?

ខៈ នៅខាងអឺ....ឈូកវ៉ា នៅឈូកវ៉ាយើងនិង!

កៈ អ៎....អញ្ចឹងអឺ....ផ្ទះនិងជាផ្ទះរបស់អ៊ុំតែម្តងហ៎?

ខ៖ ចាស! ជាប់ផ្ទះរបស់ខ្ញុំតែម្ដង!

ក៖ អញ្ចឹងអ៊ុំផ្លាស់មកនៅទីនេះប៉ុន្មានឆ្នាំហើយ?

ខ៖ ខ្ញុំនៅយូរហើយយើងនៅឥឡូវអ៎....អត់ទេយើងគិតថាបើឥឡូវខ្ញុំឥឡូវនិងខ្ញុំអាយុសែសិបហាសិបឆ្នាំ(៤០ទៅ៥០ឆ្នាំ) ជាងហើយ!

ក៖ អូ....យូរហើយណ៎អ៊ុំតាំងពីបែកប៉ុលពតមក!

ខ៖ អឺម....

ក៖ ពេលបែកប៉ុលពតមកអ៊ុំស្រីមករស់នៅទីនេះតែម្ដង?

ខ៖ ពេលបែកប៉ុលពតភ្លាមខ្ញុំមកនៅនេះតែម្ដង!

ក៖ ចាស! អ៊ុំស្រីហើយអឺ....សព្វថ្ងៃនិងអ៊ុំស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ខ្ញុំមានអាយុហាសិបពីរឆ្នាំហើយ (៥២ឆ្នាំ)!

ក៖ អ៊ុំស្រីកើតក្នុងថ្ងៃ ខែ ឆ្នាំណាដែរ?

ខ៖ ហេ....អត់ដឹងភ្លេចអស់ហើយអត់ចាំទេ!

ក៖ ចាស! អ៊ុំចុះអត្តសញ្ញាណប័ណ្ណអ៊ុំស្រីមានដែរឬទេ?

ខ៖ មានតែនៅៗក្នុងផ្ទះឯណោះ!

ក៖ ចុះថ្ងៃ ខែ ឆ្នាំខ្មែរយើងដូចជាឆ្នាំ ជូត ឆ្លូវ ឆ្នាំសត្វអីណាស់ ដូចជាឆ្នាំជូន ឆ្លូវ អីនិងអ៊ុំមានចាំទេ?

ខ៖ ខ្ញុំចាំខ្ញុំកើតអឺ....នៅឆ្នាំមមី!

ក៖ អ៊ុំស្រីកើតនៅឆ្នាំមមីហ៎ !

ខ៖ ចាស! (សើច)

ក៖ ចាស! (សើច) ហើយអ៊ុំហើយអឺ....សព្វថ្ងៃនិងអ៊ុំមានក្រុមគ្រួសារហើយឬនៅ?

ខ៖ មានគ្រួសារហើយ នោះគ្រួសារខ្ញុំហ៎!

ក៖ គាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ គាត់ឈ្មោះ អ្នក ប៊ុណ្ណា!

ក៖ គាត់ជាអ្នកស្រុកណាដែរអ៊ុំ?

ខ៖ គាត់អ្នកស្រុកជាមួយគ្នានៅខេត្តកំពតជាមួយគ្នា!

ក៖ អូ....ចុះអ៊ុំស្រីរៀបការនិងដោយសារការស្រលាញ់គ្នា ឬក៏ឪពុកម្ដាយជាអ្នករៀបចំទុកដាក់អោយអ៊ុំ?

ខ៖ កាលជំនាន់និងម៉ែឪជាអ្នករៀបចំទុកដាក់អោយ!

ក៖ អូ....(សើច) អញ្ចឹងអ៊ុំស្រីអត់ដែលធ្លាប់ស្គាល់គ្នាពីមុនមកទេ?

ខ៖ អត់ដែលស្គាល់គ្នាទេ!

ក៖ ហើយអឺ....នៅពេលរៀបការនិងអ៊ុំស្រីមានអាយុប៉ុន្មានដែរ?

ខ៖ ចាស...?

ក៖ អ៊ុំស្រីរៀបការនៅអាយុប៉ុន្មានដែរ?

ខ៖ ខ្ញុំរៀបការនៅអាយុប្រាំបីដណ្ដប់ (១៨ឆ្នាំ) ដប់ប្រាំបីឆ្នាំ!

ក៖ អ៊ុំស្រីរៀបការលឿនដែរនិងអ៊ុំកាលនិង!

ខ៖ និងហើយ(សើច)!

ក៖ (សើច) ហើយអឺ....អ៊ុំស្រីមានកូនប៉ុន្មាននាក់ដែរ?

ខ៖ បាស.... អ្នកណាគេជាអ្នកលាបអោយ អត់ទេៗអត់ដឹងទេ (មានសំលេងក្មេងនិយាយនៅពីក្រោយ)!

ក៖ អ៊ុំស្រីមានកូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានកូនពីរនាក់!

ក៖ គាត់អឺ....គាត់មានឈ្មោះអីគេខ្លះទៅអ៊ុំ?

ខ៖កូនខ្ញុំឈ្មោះ អ្នក សុខណា អ្នក សុខនឿង

ក៖ គាត់រៀបការហើយអស់ឬនៅ?

ខ៖ រៀបការរួចអស់ហើយ!

ក៖ អូ....អ៊ុំមានចៅហើយណ៎អ៊ុំណ៎!

ខ៖ មានចៅហើយខ្ញុំមានចៅមួយ!

ក៖ មានចៅមួយ គាត់អឺ....សព្វថ្ងៃរស់នៅជាមួយអ៊ុំដែរឬក៏រស់នៅផ្ទះផ្សេងគ្នា?

ខ៖ រស់នៅបែកផ្ទះគ្នាអស់ហើយកូនប្រុសៗនៅបែកគ្នាអស់ហើយ!

ក៖ គាត់នៅភ្នំពេញដែរហ៎អ៊ុំ?

ខ៖ កូនមួយនៅខាងចោមចៅ កូនមួយទៀតនៅខាងពោធិសាត់ ទៅនៅនិងទៅរកស៊ីនៅនិង!

ក៖ អ៎....

ខ៖ ចាស!

ក៖ គាត់រកស៊ីខាងអីគេដែរអ៊ុំ?

ខ៖ ប្រពន្ធកាត់ដែរវាធ្វើការសន្តិសុខនៅយាមតាម....(ស្តាប់មិនបានច្បាស់) ទើបតែផ្លាស់ទៅ!

ក៖ អូ....ចាស!

ខ៖ ចាស!

ក៖ អ៊ុំស្រីមានកូនស្រីមួយកូនប្រុសមួយមែន?

ខ៖ អត់មានកូនទេស្រី កូនខ្ញុំប្រុសទាំងពីរ!

ក៖ កូនប្រុសទាំងពីរហ៎!

ខ៖ ចាស!

ក៖ អូ....ចាស ខ្វះតែកូនស្រី (សើច)!

ខ៖ អត់ផង!

ក៖ ចុះអ៊ុំមានគំរោងចង់យកកូនស្រីទេ?

ខ៖ អត់ទេយើងចាស់អស់រដូវអីហើយ!

កៈ អឺម....

ខៈ ចាស់ហើយយើងអស់រដូវអីហើយ យើងមានតែកូនពីរនិង!

កៈ អឺម....

ខៈ ចាស!

កៈ ចុះអ៊ុំអឺ....កូនទាំងពីររបស់អ៊ុំនិងគាត់មានដែលឧស្សាហមកលេងទេ?

ខៈ មកលេងដែលមកជាហូរហែរ បើថ្ងៃសៅអាទិត្យទៅគេមក បើថ្ងៃណារវល់ខ្លាំងគេអត់បានមកទៅ វានៅធ្វើការធ្វើអីផង!

កៈ ចាស! ត្រូវហើយអ៊ុំ!

ខៈ ដូចថាយើងអត់សូវយើង....!

កៈ អ៊ុំឥឡូវរាងរវល់ដែរ!(មានសំលេងរមខានពីខាងក្រៅ)

ខៈ ឧបម៉ាថា....ទិញទឹកអំពៅមួយថង់ហ៎?

កៈ ចាស! អ៊ុំស្រីសព្វថ្ងៃអ៊ុំមានមុខរបរជាអ្វីដែរ?

ខៈ មុខរបររបស់ខ្ញុំមានលក់នំ ស្វាយទឹកអំពៅនិងខ្ញុំលក់តែការងារនឹង!

កៈ អ៊ុំលក់និងមាននំអីមាននំអីនិង!

ខៈ ខ្ញុំលក់នំប៉ុន្តែវាឥឡូវមានភ្លៀងអញ្ចឹង បន្តិចទៀតបានទិញនំយកមកលក់វិញ!

កៈ ហើយអ៊ុំប្រកបមុខរបរនេះប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំលក់យូរហើយ ខ្ញុំលក់តាំងតែពីមានកូននៅតូចៗដល់ឥឡូវកូនធំៗអស់ហើយលក់តែនៅនឹងរហូតមុខរបរមានតែប៉ុននឹង!

កៈ ហើយអញ្ចឹងអឺ....វាអាចផ្តល់ប្រាក់ចំណូលអោយអ៊ុំស្រីបានប៉ុន្មានដែរ?

ខៈ ខ្ញុំបើលក់ដាច់ទៅបានច្រើនដែរបើលក់អត់ដាច់បានប្រាំម៉ឺន ប្រាំមួយម៉ឺនរៀលអញ្ចឹងទៅណាស់ យើងដូចថាវាបានល្មមនិងចិញ្ចឹមយើង ពីព្រោះឥឡូយើងលែងចិញ្ចឹមកូនហើយនៅតែពីនាក់តានិងយាយនិងទៅណាស់ ចាស !

កះ ចាស! និងហើយ!

ខះ ដូចថាវាអត់ពិបាកដែរ!

កះ ចាស!

ខះ ចាស! យើងមានមុខរបរអីនិងទៅវាបានគ្រាន់មួយរស់ៗដែរវាមិនយ៉ាប់ពេកវាបានមួយរស់ៗដែលណាអូនវាមិនរណ្តាប់រណ្តួស(វេទនា) ពេកវាធម្មតាៗ!

កះ ចាស! អញ្ចឹងអឺ....មុខរបរទាំងអស់និងវាអាចជួយអោយអ៊ុំជាមួយនិងអឹម....!

ខះ បានៗវាជួយបាន!

កះ ហើយអ៊ុំស្រីនិងអាចមានសល់ប្រាក់សំរាប់ថ្ងៃអនាគត់ទៀតទេអ៊ុំ?

ខះ មានមិនច្រើនទេអូនវា....យើងរកបានអញ្ចឹងទៅ ដូចថាសល់តិចតួចគាត់ចង់បានតុកតុកអញ្ចឹងទៅយើងមិនដកយកលុយនិងទៅទិញសិនទៅ
ហើយយើងខ្វះខាតអីយើងធ្វើការខ្ចីអង្គការបន្តិចបន្តួចទៅណាស់ និងហើយយើងជួយគ្នាទៅ!

កះ ចុះទិញតុកតុកបានហើយឫនៅអ៊ុំ?

ខះ ទិញបានហើយនោះតុកតុកព័ណក្រហមនោះ!

កះ អឹម....ចាស អបអរសោរទរផងអ៊ុំ!

ខះ ចាស! ចាស! កាលមុនយើងរត់តែម៉ូតូទេ ដល់គាត់ចង់បានអា(តុកតុក)និងយើងរាងចំណាស់ៗហើយយើងទិញអានិងតែម្តងទៅណាអូនដល់ពេលគាត់ចង់បានហើយយើងមានតែនេះចេះតែផ្សែរផ្សំគ្នា(សន្សំលុយ)មកអញ្ចឹ លុយយើងលក់មកយើងទិញអានិងចាស លក់ម៉ូតូលក់អីនិងយើងថែមលុយទិញអានិងតែម្តងទៅ! (មានសំលេងរំខានពីខាងក្រៅ)

កះ ចាស! ចាស!

ខះ យើងខ្ចីអង្គការខ្លះទៅណាស់ (សើច)!

កះ អ៊ុំស្រីយកលុយអង្គការណាដែរអ៊ុំ?

ខះ យកអង្គការ....អានិងនិយាយរួមទៅអឹម....អង្គការអត់ទេវាអញ្ចេះបើនិយាយរួមខ្ញុំយកលុយនិងយើងបង់ពាក់កណ្តាលអានិងគេហៅអង្គការអីទេ

យើងបង់រំលោះកាលនិង លល់តែពីររយដុល្លា(២០០$) ទៀតនិងអស់ហើយ ចាស អញ្ចឹងយើងទិញបើពីពាន់ប្រាំបីរយហាសិបដុល្លា (២៨០០$) យើងបង់ជាងពាក់កណ្តាល យើងបង់ពីរពាន់ដុល្លា (២០០០$) ហើយនិង អ៊ុំនៅជំពាក់គេមិនដល់មួយពាន់ដុល្លាផង(១០០០$) បើនិយាយទៅយើងថាមួយពាន់ដុល្លា (១០០០$) ទៅចុះប៉ុន្តែឥឡូវខ្ញុំជំពាក់គេតែពីររយដុល្លាទេ!

ក៖ អូ....

ខ៖ ចាស! ពីព្រោះយើងនៅបង់អោយគេដែរ!

ក៖ ចាស! អ៊ុំស្រីដល់ពេលអញ្ចឹងមុខរបររបស់អ៊ុំស្រីរាល់ថ្ងៃអ៊ុំស្រីអាចនិងធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែរ ម៉ោងដែលអ៊ុំលក់ហាស?

ខ៖ ខ្ញុំលក់ចាប់ពីម៉ោងប្រាំពីរហ្វេតដល់ម៉ោងប្រាំល្ងាចឈប់ហើយ!

ក៖ ចាស! អញ្ចឹងលក់រាល់ថ្ងៃម៉ងអ៊ុំហ៎?

ខ៖ ចាស! លក់រាល់ថ្ងៃនិង!

ក៖ អ៊ុំលក់ពេលថ្ងៃបុណ្យថ្ងៃទានអីដែរ?

ខ៖ ថ្ងៃបុណ្យថ្ងៃទាន ដូចថាថ្ងៃណាររល់ៗអញ្ចឹងអត់លក់ដែរ ថ្ងៃបុណ្យថ្ងៃទានអញ្ចឹងបើបងប្អូនបបួលទៅដើរលេងទៅដើរលេងជាមួយបងប្អូនទៅ ចាស វាមិនអាជីពរហ្វេតទេ ចាស! (មានសមលេងរមខានពីខាងក្រៅ)

ក៖ អ៊ុំអត់មានស្តាយលក់ថាថ្ងៃបុណ្យអញ្ចឹងមានមនុស្សច្រើនអីទេ?

ខ៖ អត់ទេបុណ្យអញ្ចឹងវាអត់សូវមានមនុស្សប៉ុន្មានទេ យើងអូនអើយយើងរកស៊ីដែរគេហៅដើរទៅអត់មានស្តាយទេ នៅស្តាយអីអូនគេហៅទៅដើរលេងទៅដើរលេងនិងគេសិនទៅណាស់ កុំស្តាយ បើគេហៅទៅអត់ស្គាល់អញ្ចឹងយើងថាហ៊ឹម....គួរអោយស្តាយហើយបើឡានគេហៅទៅយើង មានអស់លុយមកពីណាយើងទៅជាមួយបងប្អូន (សើច)!

ក៖ ទៅដើរលេងអោយសប្បាយសិនហើយ! (មានសំលេងរំខានពីខាងក្រៅ)

ខ៖
អូនអើយយើងមិនសប្បាយណាស់ណាទេវាគ្រាន់តែថាយើងចំណាស់និងទៅហើយយើងកុំគិតតែធ្វើការមិនដឹងខំប្រឹងទៅណាទេ រកៗមិនដឹងងាប់មិនដឹងរស់ទេហេ!

ក៖ ចាស! ត្រូវហើយអ៊ុំ!

ខ៖ ចាស! នេះអូននេះ!

ក៖ គិតតែថាកូនក្មេងក៏វាចង់សប្បាយយើងមិនចង់សប្បាយទេ ប៉ុន្តែវាពេលយើងទៅស្រុកគេទៅអឺ....យើងមើលទៅស្រុកគេវាស្អាតអញ្ចឹង យើងទៅក្រចេះស្ទឹងត្រែងអីនិងទៅ យើងឧទាហរណ៍ថាអឺ....ព្រះវិហារអញ្ចឹង យើងឧទាហរណ៍យើងអត់ដែលស្គាល់អញ្ចឹងយើងទៅៗយើងទៅជាមួយគេទៅបានស្គាល់និយាយចេះហើយ បើនៅស្តាយលក់គឺអត់ទេ (សើច)!

ក៖ (សើច) ចាស!

ខ៖ ខ្ញុំអត់ស្តាយទេ!

ក៖ ទៅដើរហើយពេលមកវិញស្រស់ស្រាយ!

ខ៖ និងពេលយើងទៅនិងមើលឃើញប្រទេសគេអញ្ចឹងទៅណាអូន ហើយពេលយើងទៅវាឧបមាថាគេលក់មិចអីមិចខ្លះ មនុស្សយើងអាចមានការផ្លាសប្តូក៏មានដែរណាស់!

ក៖ ចាស!

ខ៖ អញ្ចឹងយើងចង់លក់ផ្ទះរបស់យើងទៅរកស៊ីនៅនិងក៏មានដែរ!

ក៖ ចាស!

ខ៖ ឥឡូវជឿឫក៏អត់ទេ?

ក៖ ចាស!

ខ៖ ចាស! អានិងយើងគិតអញ្ចឹងទៅ (សើច)!

កៈ ចាស! អ៊ុំ (សើច) និងហើយ ហើយអឺ....សំរាប់អឺ....ការធ្វើដំណើររបស់អ៊ុំអីនិងក្នុងមួយឆ្នាំអ៊ុំស្រីអាចចេញទៅដើរលេងបានប៉ុន្មានដងដែរ?

ខៈ អឺម....អត់ទៀងអោយតែគេតេហៅទៅប្រុចៗ!

កៈ ចាស!

ខៈ ពីព្រោះឥឡូវយើងអត់មានកូនតូច!

កៈ ចាស!

ខៈ ចាស! គេមានកូនមានចៅទៅគេយកម៉ែឪគេទៅចិញ្ចឹង!

កៈ ទៅដើរលេងជាមួយអ្នកជិតខាងហាំអ៊ុំហាំ?

ខៈ ប្អូនៗទៅជាមួយប្អូន!

កៈ ទៅជាមួយបងប្អូនបង្កើត?

ខៈ ចាស! ប្អូនៗបង្កើត ទៅជាមួយប្អូនស្រី ឥឡូវថ្ងៃ២១និងគេហៅទៅស្រុកទៀតហើយ

កៈ អូ....

ខៈ គេហៅអោយទៅឡើងផ្ទះ អានិងទៅឡើងផ្ទះបងនៅឯស្រុកហាស!

កៈ ចាស!

ខៈ អើ....ហើយយើងអត់មានអស់លុយទេ កូនវានៅស្រុកគេនៅប្រទេសកូរ៉េនៅអីនិងអញ្ចឹងគេអោយតែយើងទៅទេ ទៅជួបជុំគ្នា ចាស ឡើងផ្ទះថ្មី!

កៈ ចាស!

ខៈ បើថាប្តីគាត់អត់ទៅខ្ញុំទៅតែម្នាក់ឯងជាមួយប្អូនៗនិងទៅ ទៅដេកមួយយប់អីមកវិញមក ចាស!

កៈ ចាស! ចុះអ៊ុំមានបងប្អូននៅក្រៅប្រទេសដែរឬទេ?

ខៈ ខ្ញុំមានៗពូគាត់នៅក្រៅប្រទេស ប៉ុន្តែគាត់ស្លាប់ហើយនៅតែសាច់ថ្លៃ!

កៈ គាត់នៅប្រទេសណាដែរអ៊ុំ?

ខៈ គាត់នៅប្រទេសអាមេរិច!

កៈ ចាស!

ខៈ ប៉ុន្តែអត់ដែលទំនាក់ទំនងទេ ពេលគាត់មកអញ្ចឹងគាត់អោយលុយ បើថារឿងសុំលុយរឿងអីគឺអត់ទេ!

កៈ អឺម....គាត់នៅរដ្ឋអីគេដែរអ៊ុំ?

ខៈ អឺ....រដ្ឋមិនដឹងរដ្ឋអីទេនៀកខ្ញុំ....នៅរដ្ឋតិចសាសន៍ៗ!

កៈ ចាស! នៅនិងមានជនជាតិខ្មែរៗអីរាងច្រើន!

ខៈ និងហើយៗនៅខ្មែរៗដូចគ្នាច្រើន!

កៈ ចុះគាត់រកស៊ីអ្វីដែរនៅទីនោះ?

ខៈ ខ្ញុំអត់ថា អឺ....គាត់ធ្វើការអង្គការ គាត់ធ្វើការអង្គការ! (មានសំលេងរំខានពីខាងក្រៅ)

កៈ ចុះអឺ....គាត់ឧស្សាហ៍មកលេងស្រុកខ្មែរយើងដែរទេអ៊ុំ?

ខៈ គាត់ឧស្សាហ៍មកតើ ប្អូនស្រីគាត់រស់នៅទីនេះ ប្អូនខាងប្រពន្ធរបស់គាត់!

កៈ អឹម....ហើយទៅអឺ....បងប្អូនរបស់អ៊ុំដែរនៅខាងសហរដ្ឋអាមេរិចនិងគាត់មានដែលធានាអ៊ុំអោយទៅលេងទេ?

ខៈ អត់ទេគាត់គ្រាន់តែត្រូវជាពូរបស់ខ្ញុំនិង ខ្ញុំបងប្អូនខាងប្រុស ពូខ្ញុំនិងគាត់ស្លាប់បាត់ហើយនៅខាងស្រី ខាងស្រីដូចថាគេមកៗធម្មតាៗនិងគេអោយលេខមកខ្ញុំអត់សូវទំនាក់ទំនងផង កុំអោយថាយើងថាអឹម....បើពូរបស់ឯងហើយនៅតែសាច់ថ្លៃកុំអោយគេថាងាកសុំងាកសុំគឺអត់ទេ!

កៈ អឹម....

ខៈ គឺអត់ទេ!

កៈ ចាស!

ខៈ ជីវិតយើងប៉ុន្មានគឺប៉ុននឹង(សើច) ដុល្លាយើងមិនសូវស្គាល់ច្រើនទេត្រឹមមួយរយដុល្លាអីនិងយើងដូរទៅស្គាល់ហើយ!

កៈ ចុះអ៊ុំមានបងប្អូនស្លាប់ក្នុងជំនាន់ប៉ុលពតទេ?

ខៈ ស្លាប់អឺ....ស្លាប់មួយប្រហែលអឺ....ប្រាំបីខែមិនដល់មួយខួបទេកូននិងហ៎កូនស្រីហ៎វាប្អូនម៉ែអាលែងតែទៅធ្វើការហើយយើងមើលប្អូនយើងរាងនៅស្ទើរៗមើលហើយវាក្តៅខ្លួនពេលម៉ែមកវិញវាស្លាប់ទៅ ចាស !

កៈ អឺម....កូរអោយសោកស្តាយណាស់!

ខៈ ចាស! និងហើយធ្វើមិចយើងមើលវាមិចនិងបានជិតដល់ម៉ែទៅធ្វើការទៅធ្វើអីនិងទៅ!

កៈ កាលនិងអឺ....ដូចថាចំណីអាហារថ្នាំសង្កូវអីនិងមិនសូវមានផង!

ខៈ អឺ....និងហើយៗ!

កៈ ហើយអ៊ុំទាន់និងភ្នែកតែម្តងមិចក៏ស្លាប់អញ្ចឹងវិញ!

ខៈ ឃើញផ្ទាល់និងភ្នែកតែម្តងពីព្រោះអីខ្ញុំជាអ្នកមើល!

កៈ អឺម....

ខៈ ក្តៅខ្លាំងម៉ែមកវិញស្លាប់!

កៈ កូនស្រីឬកូនប្រុសអ៊ុំ?

ខៈ កូនស្រីគិតទៅជំនាន់ប៉ុលពតបានមួយនិង បានមួយស្រីនិងស្លាប់ (មានសំលេងរំខានពីខាងក្រៅ)!

កៈ អញ្ចឹងកាលនិងគ្រួសាររបស់អ៊ុំគេជំលៀសទៅនៅជុំគ្នាហ៎?

ខៈ គេជំលៀសនៅតែទាំងអស់និងឪពុករបស់ខ្ញុំគេជំលៀសទៅខាងកំពតស្រុករបស់គាត់!

កៈ ចុះកាលជំលៀសនិងដើរទៅហ៎អ៊ុំ?

ខៈ ដើរទៅ!

កៈ ពីភ្នំពេញ....?

ខៈ ចាស! ដឹងក្តីហើយខ្ញុំធំដឹងក្តីហើយ ខ្ញុំនៅជិតវត្តផ្ទះរបស់ខ្ញុំកាលពីសង្គមចាសនៅជិតវត្តនិង វត្តនិងនៅតាំងពីរជំនាន់និងអញ្ចឹងហើយស្គាល់ទេ!

កៈ អឹម....ឆ្ងាយណាស់អញ្ចឹងពីព្រោះដើរពីភ្នំពេញទៅកំពត ប៉ុន្មានថ្ងៃបានទៅដល់?

ខៈ ទៅអស់បីយប់បួនថ្ងៃ!

កៈ ដេកតាមផ្លូវខ្លះទៅ?

ខៈ និងហើយដេកតាមផ្លូវខ្លះទៅដេកទៅអោយតែគេអោយដេក(សើច)!

កៈ (សើច) ហើយអឺ....កាលនិងអ៊ុំអាយុប៉ុន្មានឆ្នាំហើយ?

ខៈ កាលនិងខ្ញុំអាយុប្រាំបីឆ្នាំ!

កៈ អូ....កាលនិងនៅក្មេង!

ខៈ ខ្ញុំនៅរៀន!

កៈ កាលនិងគេប្រើអោយអ៊ុំធ្វើអ្វីខ្លះទៅ?

ខៈ គេអោយមើលៗក្មេងៗមើលតូចៗអញ្ចឹង ហើយគេអោយកាប់កណ្តៀងខែតអីកាប់និង អោយមើលក្របីអត់ចេះមើលទេវាស្នែងវាវែងៗពេកខ្លាច!

កៈ អូ....ហើយគេអោយរបបអាហាររបស់អ៊ុំយ៉ាងមិចដែរ?

ខៈ អើយ....កាលនិងកេអោយហូបឆ្អែតៗគេមិនដែលយើងអត់ដឹងខ្យល់ថាអត់មានអីហូបអីនិងទេ គឺមានហូបរហូត!

កៈ គេអត់ដែលធ្វើបានអ៊ុំទេហ៎?

ខៈ គេអត់ដែលធ្វើបានទេ!

កៈ គេអត់ដែលវៃអត់ដែលអីទេ?

ខៈ អត់ទេ យើងមើលតែក្មេង!

កៈ ចុះក្នុងជំនាន់និងអ៊ុំមានចងចាំទិត្តភាពអ្វីខ្លះនៅក្នុងសម័យនិង?

ខៈ មានអីត្រូវចងចាំមើលក្មេងមើលអីនិងមានអីត្រូវចងចាំ!

កៈ អ៊ុំមានដែលឃើញប៉ុលពតយលទៅសំលាប់ចោលទេ?

ខៈ
អត់ទេអត់ដែលឃើញទេគេថាយកទៅភូមិៗនិងទៅមិនដឹងថាគេយកទៅសំលាប់មិនសំលាប់ខ្ញុំអត់ដឹងផង
យើងអត់ដឹងថាគេយកទៅណាយកទៅណឺយើងអត់ដឹងលឺតែគេថាទៅភូមិថ្មីភូមិអីៗគេណាយើងមិចដឹងយកទៅយើងអត់ដឹងទេយើងនៅស្ទើរយើងមិចដឹង!

កៈ អ៊ឹម....លឺតែគេនិយាយដែរ!

ខៈ
លឺតែគេនិយាយដល់ពេលបែកពីប៉ុលពតវិញអូ...មាន...ប៉ុលពតយកទៅសំលាប់និងបានដឹងអញ្ចឹងគេយកទៅភូមិថ្មីៗមែន!

កៈ អ៊ឹម....

ខៈ
អានិងយើងអត់ដឹងទេអត់ដឹងថាគេយកទៅណាគេថាយកទៅកសាងគេថាយកទៅផ្លាសប្តូយកទៅខេត្តភូមិនេះៗអញ្ចឹងអ្នកណាដឹងដូចយើង ឧទាហរណ៍ខ្ញុំថាធ្លាប់នៅភ្នំពេញដល់នៅភ្នំពេញអញ្ចឹងគេអោយយើងទៅស្រុកចុះបើដល់ពាក់កណ្តាលផ្លូវគេវាយចោលទៅយើងមិចដឹងមិនអញ្ចឹងមិនដឹងថាយើងទៅដល់គោលដៅយើងឫមិនដល់ទេ!

កៈ អ៊ឹម....ចាសអ៊ុំហើយអឺ....នៅពេលកាលជំនាន់និងគេមានធ្លាប់បង្អត់បាយអីអ៊ុំទេ?

ខៈ អត់ទេអត់មានទេ!

កៈ អត់ទេអត់មានដែលសោះម៉ង?

ខៈ អត់មានទេពីព្រោះយើងនៅកូនក្មេងតូចៗអញ្ចឹង!

កៈ នៅក្មេង អញ្ចឹងគេអត់ៗដូចជាអឺ....ពេលដែលអ៊ុំគេអោយរបបអាហារអីមកអញ្ចឹង...!

ខៈ អត់ទេៗអត់មានទេ!

កៈ អ៊ុំអត់មានថាធ្លាប់ឃ្លានអីដែរឬទេ? (សើច)

ខៈ អត់ទេ អត់ៗមានទេពីព្រោះគេអោយមើលកូនអ្នកធំ គេអោយមើលកូនអ្នកធំហ៎!

កៈ ចាស! ចុះអ៊ុំកាលសម័យប៉ុលពតនិងអ៊ុំធ្លាប់លឺឪពុកម្តាយរបស់អ៊ុំបាននិយាយប្រាប់អ៊ុំពីអ្វីខ្លះដែរឬទេ?

ខៈ អត់មាននិយាយអីទេគ្រាន់ថាយើងចេញពីភ្នំពេញទៅកាត់គ្រាន់តែថាកុំអោយនិយាយអីគេអញ្ចឹងពីព្រោះខ្លាចគេយកទៅវាយចោលសំរាប់អីអញ្ចឹងទៅណាស់!

កៈ អ៎....

ខៈ គាត់អត់មាននិយាយអីទេ!

កៈ ចាស!

ខៈ យើងមិចហ៊ានយើងអ្នកថ្មីយើងមិនហ៊ានជចាមួយគេអ្នកចាសទេ!

កៈ ចាស!

ខៈ ឪម៉ែប្រាប់ធម្មតាកុំអោយយើងនិយាយថាចាយលុយចាយអីនិងកុំអោយនិយាយអញ្ចឹងយើងអត់និយាយទេយើងនៅតែធ្វើការមើលកូន មើកកូនអោយគេអ្នកធំៗអញ្ចឹងណាស់អាមេគីគេជាគណះកង គណះឃុំយើងទៅមើលក្មេងយើងពរអញ្ចឹងទៅណាស់មាននិយាយអីគាត់អត់មាននិយាយអីផង! (មានសំលេងរំខានពីខាងក្រៅ)

កៈ ក្មេងក្នុងជំនាន់និងប្រហែលជាប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ អ៊ឹម....ក្មេងជំនាន់និងវាប្រហែលមើលបើមើលទៅតាមអាយុប្រហែលដូចជាស្រករ យើងបងប្អូនយើងតិចតួចនិង សាមជាងសាមក្រាស់ជិតសែសិចឆ្នាំអីអញ្ចឹងទៅណាស់បើយើងហាសិបឆ្នាំជាងហើយ!

កៈ អូ....ដំណើរៗគ្នាដែរ!

ខៈ ចាស!

កៈ ចុះអ៊ុំពេលដាច់ប៉ុលពតមកអ៊ុំមានអីចងចាំអីគេដែរ ពេលដាច់ប៉ុលពតមក?

ខ៖ អត់មានចងចាំអីទេគ្រាន់តែថាដាច់ឪម៉ែខ្ញុំគាត់យកមកនៅភ្នំពេញតែម្តងអត់នៅនិងមក....!

ក៖ កាលជំនាន់និងអ៊ុំដើរមកហ៎?

ខ៖ ដើរមក!

ក៖ អូ....

ខ៖ អ៎....ជិះរទេះគោ!

ក៖ អឹម....

ខ៖ បររទេះគោមក ពេលខ្ញុំមក (មានសំលេងរំខានពីខាងក្រៅ)

ក៖ ហើយអញ្ចឹងអី....ឪពុកនិងអ្នកម្តាយអ៊ុំអីនិងកាលនិងគាត់មកទាំងអស់គ្នាតើហី?

ខ៖ មកទាំងអស់គ្នាមកតែទាំងអស់និងបងប្អូនទាំងអស់!

ក៖ មកជុំគ្នាតែម្តង?

ខ៖ ចាស! មកជុំគ្នាទាំងអស់បងប្អូទាំងអស់មកទាំងអស់!

ក៖ ចាស! ពីព្រោះអីគេអត់មានបំបែកគ្នាទេ?

ខ៖ អត់ទេៗនៅក្មេងៗគេអត់មកបំបែកផង (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ដល់ពេលបានមកដល់នេះតើអ៊ុំបានសិក្សាអីដែរទេ?

ខ៖ បានរៀន!

ក៖ បានរៀនបន្តទៀត?

ខ៖ ចាស! បានរៀន!

ក៖ អ៊ុំរៀននៅសាលាណាដែរ?

ខ៖ នេះរៀននៅសាលាយើងវត្តនាគវ័ន្ត!

ក៖ សាលានាគវ័ន្ត!

ខ៖ ចាស!

កៈ ចាស! ចុះការសិក្សាររបស់អ៊ុំដល់កំរិតណាដែលអ៊ុំ?

ខៈ កាលនិងយើងរៀនត្រឹមថ្នាក់ទីប្រាំពីរប្រឡងគ្រូហាស!

កៈ អឹម....

ខៈ ថ្នាក់ទីបួនឌីប្លូម បានរៀនថ្នាក់ទីបួន!

កៈ រៀនថ្នាក់ទីបួន!

ខៈ ទីបួនជំនាន់និងប៉ុន្តែយើងប្រឡងឌីប្លូមហាស!

កៈ ចាស!

ខៈ ចាស!

កៈ អញ្ចឹងអឺ....អ៊ុំរៀនដល់ថ្នាក់ទីបួនអ៊ុំរៀនបន្តដល់ថ្នាក់ទីប្រាំពីរឬក៏បញ្ឈប់ត្រឹមនិង?

ខៈ អត់ផងខ្ញុំឈប់ត្រឹមថ្នាក់ទីប្រាំពីរ អឹស....ត្រឹមថ្នាក់ទីបួននិងតែម្តង (មានសំលេងរំខានពីខាងក្រៅ)!

កៈ អញ្ចឹងអ៊ុំឈប់រៀនត្រឹមថ្នាក់ទីបួននិងអញ្ចឹងអ៊ុំអាចចេះសរសេរចេះអានអីបានហើយនេះអ៊ុំ?

ខៈ ដល់ឥឡូវយើងគិតអញ្ចេះដល់តែពេលយូរៗទៅ ដល់ឥឡូវគ្រាន់តែថាមើលអក្សររាងដាច់ៗដែរ សរសេរអីនិងរាងអានបានប៉ុន្តែដល់ពេលពាក្យអីរាងជ្រៅៗខ្ញុំរាងមិនសូវនេះហាសយើងចង់រាងភ្លេចៗ(សើច)!

កៈ ចាស!

ខៈ ចាស!

កៈ ហើយអ៊ុំចេះប៉ុន្មានភាសាដែរ?

ខៈ អត់តេយើងរៀនតែភាសាខ្មែរ រៀនតែខ្មែរអីនិង!

កៈ អ៊ុំរៀនតែភាសាខ្មែរទេហ៎?

ខៈ រៀនតែខ្មែរអីនិងពេលមុនមិនទាន់មានភាសាអង់គ្លេសមកពីណានៅជំនាន់និង!

ក៖ អឺម....ហើយកាលជំនាន់និងអឺប្រឡងទីប្រាំពីរ ប្រឡងបាក់ឌុបជំនាន់មុនស្មើរនិងទីដប់ពីសម័យឥឡូវ!

ខ៖ និងហើយៗ អត់ទេយើងប្រឡងថ្នាក់ទីបួន ទីបួននិងបាក់ឌុបហា ស្មើនិងឌីប្លូម!

ក៖ ឌីប្លូមថ្នាក់ទីប្រាំបួនអញ្ចឹងថ្នាក់ទីប្រាំពីស្មើរនិងថ្នាក់ទីដប់ពីរ?

ខ៖ ចាស! ចាស! និងហើយគេប្រឡងធ្វើគ្រូធ្វើអីនិងហំ កាលនិង!

ក៖ អឺម....ហើយចុះអ៊ុំកាលនិងម៉េចបានអ៊ុំបញ្ឈប់ការសិក្សារត្រឹមថ្នាក់ទីបួនអញ្ចឹង?

ខ៖ បើម៉ែឪ ម៉ែរបស់ខ្ញុំគាត់ចង់អោយខ្ញុំមានគ្រួសសារហើយអញ្ចឹងណាស់!

ក៖ អឺម....

ខ៖ យើងមានអាយុច្រើនហើយ ដូចថាយើងមានអាយុរាងច្រើនអញ្ចឹងតាមឪពុកម្តាយ ប៉ុន្តែគ្រួសារខ្ញុំនៅស្រុកនិងដែរនិងប៉ុន្តែខ្ញុំអត់ស្គាល់គ្នា គ្រាន់តែថាម៉ែគាត់ក្នុងជំនាន់ប៉ុលពតចិញ្ចឹមម៉ែខ្ញុំអញ្ចឹងទៅណាស់!

ក៖ អឺម...

ខ៖ អញ្ចឹងយើងតាមឪពុកម្តាតក៏តាមគាត់អញ្ចឹងទៅណាស់ខ្ញុំរៀបការនៅស្រុកហំ (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាស! អញ្ចឹងអឺ....កាលនិងអ៊ុំឈប់រៀនភ្លាមរៀបការភ្លាម?

ខ៖ អត់ទេខ្ញុំឈប់បានពីរឆ្នាំបីឆ្នាំនោះ មួយឆ្នាំៗ!

ក៖ អញ្ចឹងពេលអ៊ុំឈប់រៀនអ៊ុំធ្វើការអ្វីដែរ?

ខ៖ ខ្ញុំនៅលក់ដូរ!

ក៖ អ៊ុំនៅលក់ដូរ?

ខ៖ នៅលក់ជាមួយម្តាយខ្ញុំលក់អញ្ចឹងលក់នៅផ្ទះលក់នៅអឺ....!

ក៖ អ៊ុំលក់បង្អែមក៏អឺ....?

ខ៖ អត់ទេខ្ញុំលក់ឥវ៉ាន់ចាប់ហួយស្អីនិងជាមួយកាត់កាលនិងគាតត់នៅអឺ....គាត់នៅមានកំលាំងគា

ត់ខ្ញុំនៅជួយលក់គាត់និយាយទៅយើងនៅចិញ្ចឹងប្អូនចិញ្ចឹមអីនិងណាស់ ប្អូនមានទានណាការយើងរាងធំជាងគេយើងនៅជួយលក់ម្ដាយឪនៅធ្វើការយើងនៅផ្ទះយើងនៅគ្រងប្អូនៗ!

ក៖ ចាស!

ខ៖ និងហើយ!

ក៖ ចុះអ៊ុំកាលនិងអ៊ុំមានចង់ស្រមៃថាពេលធំឡើងអ៊ុំចង់ធ្វើអីដែរឬទេ?

ខ៖ យើងចង់តែពី....កាលនិងខ្ញុំថាអត់ទាន់មានប្ដីខ្ញុំចង់ថាខ្ញុំចង់!រៀនបន្តខ្ញុំចង់ធ្វើខាងពេទ្យធ្មបខ្ញុំចង់រៀនពេទ្យធ្មប!

ក៖ អឺម....

ខ៖ ចាស! ឥឡូវក៏ចិត្តនៅតែចង់ដែរ (មានសំលេងរំខានពីខាងក្រៅ)!

ក៖ មូលហេតុអ្វីបានជាអ៊ុំស្រលាញ់ខាងពេទ្យធ្មបអញ្ចឹង?

ខ៖ ខ្ញុំស្រលាញ់ខាងនិងតែម្ដង ចូរចិត្តអារឿងធ្វើពេទ្យធ្មបរឿងអាពេទ្យវះកាត់អីនិងដូចជាពេទ្យធ្មបពេទ្យបង្កើត ឥឡូវនិងកុំថាទៅពេទ្យអីជូនកាលទៅខ្ញុំចូរតើខ្ញុំចង់តែម្ដងខ្ញុំចង់រៀនខាងនិង (សើច)!

ក៖ ចាស! អ៊ុំស្រលាញ់ខាងនិងតែម្ដង?

ខ៖ ស្រលាញ់ខាងនិង!

ក៖ អ៊ុំអត់ខ្លាចឈាមអីទេហ៎?

ខ៖ អត់ៗខ្លាចទេ!

ក៖ ចុះអ៊ុំមានធ្លាប់ដែរបានបង្កើតកូនគេទេ?

ខ៖ អត់ដែរទាន់ធ្លាប់បង្កើតកូនគេទេគ្រាន់តែថាអញ្ចេកយើងអី....ដូចថាយើងនៅស្រុកភូមិអីនិងគាត់ឆ្លងទន្លេពេទ្យខ្មែរនិងខ្ញុំចូរទៅតើចូរចិត្តទៅជួយគេ!

កៈ អឺម....

ខៈ តែឈាមអីខ្ញុំអត់មានខ្លាចទេ ឧបមាថាឥឡូវមានគេដួលម៉ូតូអីនិងអីណាមិនថាចាស់ឬក្មេងទេមានកមមានដំបៅអីនិងខ្ញុំចូរចិត្តខាងអញ្ចឹងៗតែម្តង!

កៈ អឺម....

ខៈ ប្អូនរបស់ខ្ញុំជេតែរហូតនិងជេខ្ញុំចង់ងាប់ហើយ!

កៈ អឺម....(សើច)មិចវិញ?

ខៈ វាថាអី....ឃើញកូនគេអ្នកក្រៅអីនិងមានកើតបូសអីនិងអោយច្របាច់អីនិងខ្ញុំចូរចិត្ត!

កៈ អឺ....(សើច) ជួយគេម៉ង!

ខៈ ចាស! វាគគ្រឿតម៉ងហាស!

កៈ ចាស!

ខៈ រឿងអាដំប៉ៅនិងឃើញគគ្រឿតម៉ងចង់តែលាងអោយស្អាតៗទៅណាស់!

កៈ អឺម....

ខៈ ឧបមាថាអឺម....ហែងអញ្ចឹងទេមើលហែងលាងអោយស្អាតៗអញ្ចឹងម៉ងហាសក្មេងៗឃើញមានដំបៅអីនិងចង់លាងអោយតែស្អាតៗដុះវាអោយស្អាតម៉ងហាសឃើញគគ្រិចអញ្ចឹង ខ្ញុំចូរចិត្តម៉ងហាស!

កៈ ចាស! ចូរចិត្តជួយគេដែរ!

ខៈ ចាស! អត់ខ្ពើមទេអត់ទេ (មានសំលេងរំខានពីខាងក្រៅ)!

កៈ តែអ៊ុំអឺ....សំរាប់អឺ....ឥឡូវនិងអឺ....អ៊ុំមានគំរោងផែនការអ្វីទៅថ្ងៃមុខដូចជាចង់ផ្លាស់ប្តូរមុខរបរឬក៏ចង់ទៅរៀនបន្តទៀតឬក៏អីទៀតអ៊ុំ?

ខ៖ យើងគិតថាយើងចំណាស់នេះហើយអូនឥឡូវយើងខំប្រឹងលក់ទៅឥឡូវផ្ទះយើងមានគិតថាឥឡូវផ្សេផ្សំលុយយើងចង់តផ្ទះមកមុខបន្តិចទៅណាស់ពីព្រោះយើងអស់លុយហើយក្មួយមិនមើលយើងទិញតុកតុកអស់លុយហើយក្មួយមិនមើល!

ក៖ ចាស!

ខ៖
អញ្ចឹងយើងផ្សេផ្សំក្រែងយើងឆ្នាំក្រោយងឹអញ្ចឹងទៅយើងថាយើងជូសជុលនៅពេលចូលឆ្នាំខ្មែរឥឡូវនិងជិតភ្ជុំហើយតិចទៀតចូលឆ្នាំហើយយើងផ្សំអោយបានត្រឹមពីរបីរយដុល្លាអីនិងទៅប្រាំរយដុល្លា
ឧបមាថាយើងជូសជុលអស់ពីរបីរយដុល្លាអីនិងចង់ថាយើងចំណាស់និងហើយយើងអត់មានកូនណាទៀតទេកូនណាអោយហូបក៏ហូបទៅកូនណាមិនអោយក៏យើងមានខ្លួនឯងដែរយើងកុំៗសុំវាយល់ហេ!

ក៖ អឺម....

ខ៖ អញ្ចឹងយើងលក់ចាប់ហួយនៅផ្ទះ!

ក៖ ចាស! អ៊ុំ

ខ៖
លក់មិនចាំបាច់ត្រូវការដើមច្រើនទេប្ដីយើងរកអានេះឥឡូវយើងថាប្ដីសុំទិញអានេះយើងទិញបានអោយអញ្ចឹងយើងនៅតែម្នាក់ឯងពេលប្ដីមកភ្នំពេញមកៗយើងនៅឈ្ងកវ៉ានេះយើងនិងយើងលក់មិនបាច់ចាំច្រើនទេដើមត្រឹមតែយើងថាត្រឹមមួយរយពីររយដុល្លាចុះយើងថាចិតសិបម៉ឺនយើងថាមួយលានទៅចុះអញ្ចឹងយើងបានហើយយើងកុំដើរផ្ទះគេអញ្ចឹងយើងបានខ្លួនឯងហើយនៅផ្ទះខ្លួនឯង ឧបមាថាលក់បានមួយម៉ឺនពីរម៉ឺនក៏យើងបានដែរមិនអញ្ចឹង!

ក៖ ចាស!

ខ៖ ឧបមាថាប្ដីរកអត់មានលុយទេគ្រាន់តែថាយើងរាងខ្វះខាតបន្តិដែរ(សើច)!

ក៖ ត្រូវហើយអ៊ុំ!

ខ៖ ជឿអត់អូនឯងជឿអញ្ចឹងហេ!

ក៖ ចាស!

ខ៖ ចាស! យើងអត់មានមកអង្គុយតែអញ្ចឹងរហូតទេ!

ក៖ ត្រូវហើយអ៊ុំ!

ខ៖
ពីព្រោះផ្ទះយើងមានយើងអត់ជួលគេទេតឡូវបានម៉ែគាត់ចែកមកអោយយើងបានលុយមកយើងបបួលទិញដី ហើយកូនមកមានឧបមាថាគេចង់បានប្រពន្ធអញ្ចឹងដូចថាគេបង្គាប់ប៉ុន្មានយើងជួយចេញវាអញ្ចឹងយើងជួយចែកវាអោយដាច់ៗម៉ងកុំអោយវាប្រាប់ប្រពន្ធវាថានិងជាផ្ទះរបស់វាទៀតនិងអត់មានទេ!

ក៖ ចាស! អ៊ុំ

ខ៖
និងឧបមាថាខ្ញុំចាសទៅធ្វើអីលែងកើតអញ្ចឹងឧបមាថាផ្ទះនិងត្រូវថ្លៃអីនិងទៅខ្ញុំលក់ទៅនៅខាងប្ដីនៅកំពតវិញ!

ក៖ អូ....ចាស!

ខ៖ ចាស! យើងចង់អញ្ចឹងវិញ ឧបមាថាយើងលក់ចែកវាតឡូវនិងប្រាប់វារួចហើយតើក្មួយខាងគាត់និងខ្ញុំចែកមួយពាន់(១០០០$) ខ្មួយខាងប្អូនស្រីគាត់និងខ្ញុំចែកមួយពាន់(១០០០$) ហើយអោយមួយពាន់ទៀតយើងអត់ទាន់ថាយើងអត់ទាន់លក់ទេផ្ទះនិង!

ក៖ គេអោយមួយពាន់ហើយហ៎អ៊ុំ?

ខ៖ យកចែកអោយប្អូនៗខាងគាត់និង ប៉ុន្តែផ្ទះខ្ញុំគេអោយពីម៉ឺនជិតបីម៉ឺនដុល្លាហើយ ចាសអញ្ចឹងយើងរស់បានហើយលុយយើងប៉ុននឹង!

ក៖ ចាស!

ខ៖ ចាស!
យើងធ្វើផ្ទះទាមមួយតូចអញ្ចឹងទៅដល់ពេលហើយអឺ....ចង់និយាយថាធ្វើផ្ទះមួយរាងមិនសូវធំប៉ុន្មានទេធ្វើរាងតូចល្មមអញ្ចឹងទៅណាស់
ប៉ុន្តែប្អូនស្រីថាមិនបាច់ធ្វើទេនៅផ្ទះឈើអញ្ចឹងទៅណាស់
តែយើងចង់ធ្វើផ្ទះទៀមប៉ុននឹងទៅយើងធ្វើផ្ទះទៀមថ្ម យើងចង់ធ្វើផ្ទះថ្ម

ប៉ុន្តែបើយើងចង់មកលេងភ្នំពេញផ្ទះបងប្អូនយើងមានមកភ្នំពេញមកទៅមកនៅផ្ទះប្អូនពីរបីថ្ងៃ ឬកន្លះខែមួយខែយើងទៅវិញទៅ ចាស ខ្ញុំអត់ចង់នៅភ្នំពេញទេ!

ក៖ អ៎....នៅនេះធុញថប់!

ខ៖ យើងដើរវាខ្ជិលណាស់អូនយើងមានលុយដែរបើកូនៗយើងអត់ទៅនៅជាមួយវាទេ វាហៅទៅនៅតែយើងអត់ទៅទេសុខចិត្តថាអត់ បានប្រាប់វាហើយ ចាស!

ក៖ ចាស! អុំផ្ទះអី....អុំដូចជាមានប្លង់រឹងទេ?

ខ៖ មានៗមានប្លង់រឹង ចាស !

ក៖ នៅក្រោយវត្តនិងហ៎អុំ?

ខ៖ អត់ទេណោះនៅណោះឥឡូវលក់ឥឡូវហើយទៅទិញនៅជិតសំរោងអណ្តែតហ៎!

ក៖ ផ្ទះនៅសំរោងអណ្តែតវិញ?

ខ៖ ហួសនិងទៀតប៉ុន្តែខ្ញុំទិញនៅនិងយូរហើយចាស (មានសំលេងរំខានពីខាងក្រៅ)!

ក៖ អូ....អុំដល់ពេលមកនេះរកស៊ីនៅនេះអញ្ចឹងអុំស្គាល់គេច្រើនហើយ?

ខ៖ ចុះនៅនេះបើនិយាយពីយើងស្គាល់គឺស្គាល់ពេកហើយ ចាស យើងស្គាល់!

ក៖ ចាស! និយាយថាយូរឆ្នាំដែរហើយអុំ?

ខ៖ មកតាំងពីកូនយើងនៅតូចៗឥឡូវកូនយើងការអស់ហើយហែងគិតមើលទៅ!

ក៖ ត្រូវហើយចុះអី....ខាងវត្តគេមានអោយអុំលក់និងមានលក្ខ័ណ្ឌអីទេក្នុងការលក់និង?

ខ៖ ខាងវត្តគេអោយយើងបោសសំអាតអោយស្អាត អញ្ចឹងយើងច្រក់សំរាមទៅឧបមាថាអី....ឡានសំរាមគេមកយើងផ្តល់លុយអោយគេមួយពាន់រៀលពីរពាន់រៀលប្រាំពាន់រៀលអញ្ចឹងទៅអោយគេជួយលើកសំរាមចេញទៅ!

ក៖ ចាស!

ខ៖ យើងចងសំរាមអោយតែស្អាតៗទៅ!

ក៖ ចាស!

ខ៖ ចាស! ពេលគេមកឃើញស្អាតគេមកយកអាំហើយ!

ក៖ ត្រូវហើយអ៊ុំ!

ខ៖ ចាស! ហើងយើងធ្វើកុះអោយគគ្រិចជីវត្ត!

ក៖ ចាស! ស្អាតទាំងអស់គ្នា!

ខ៖ ចាស! ចាស! ឥឡូវគេអនាម័យអភិវឌ្ឍន៍អូន!

ក៖ ចាស! ចុះអ៊ុំអី....ទាក់ទងជាមួយបទពិសោធន៍នៅក្នុងជីវិតរបស់អ៊ុំវិញតាំងពីតូចមកដល់ឥឡូវនិងអ៊ុំមានបទពិសោធន៍ឆ្លងកាត់នៅក្នុងជីវិតអីគេខ្លះអ្វីដែលធ្វើអោយអ៊ុំចងចាំអត់ភ្លេចសោះឡើយ?

ខ៖ អត់ទេអត់មានអីផងត្រូវពិបាកទេអត់មានអោយកូនពិបាកអីទេឪពុកម្ដាយគាត់ក៏អត់ដែលធ្វើបាបយើងដូចដែលថាគាត់ចិញ្ចឹមយើងដល់ពេលនេះអញ្ចឹងដល់ពេលកូនប្រុសពីក៏អត់មានធ្វើអោយពីបាក ចាស ដោះស្រាយដូចថាយើងលំបាកប៉ុនៗនឹងយើងចេះតែជួយដោះស្រាយគ្នាទៅ ចាស អត់មានអោយពិបាកកូនជក់ម៉ាអីអត់មានទេប្ដីរត់ម៉ូតូឌុបយើងមានតែតស៊ូអោយកូនរៀនរសហូតដល់ចប់ចុងចប់ដើម ចាស ដល់ពេលវារៀនបានមួយឆ្នាំទៅវាខំប្រឹងដើររកការងារវាធ្វើទៅផ្សំគ្នាបង់អោយអស់ថ្លៃវារៀន ចាស អញ្ចឹងណាស់អូន!

ក៖ ចាស! អ៊ុំអញ្ចឹងបទពិសោធន៍ល្អៗនៅក្នុងជីវិតល្អៗរបស់អ៊ុំវិញតាំងពីមុនរហូតមកដល់ឥឡូវនិងអ៊ុំមានចងចាំរឿដែលអ៊ុំធ្លាប់មានរឿងអ្វីមួយល្អដែលធ្វើអោយអ៊ុំនឹកឃើញហើយសប្បាយចិត្ត?

ខ៖ សប្បយចិត្តមានតើ ចាស សប្បាយចិត្ត ចាស សប្បាយចិត្តតាំងពីអើយមកអត់មានធ្លាប់ពិបាកទេគិតតែថា គិតថាឥឡូវនិងអត់មានបារម្ភណ៍អីទេ ឧបមាថាយើងចង់និយាយពីនាក់ប្ដីប្រពន្ធយើងជំពាក់គេយើងដោះស្រាយចេញអញ្ចឹងទៅណាស់យើងៗនិយាយរួមអត់មានពិបាកខ្លាំង!

ក៖ ចាស! ខ្ញុំឃើញសប្បាយចិត្តអ៊ុំមានរឿងអ្វីខ្លះដែលធ្វើអោយអ៊ុំសប្បាយចិត្ត?

ខ៖ មានរឿងដូចថាយើងមានរឿងឧទាហរណ៍ថាឯកកោអត់សប្បាយអីនិងយើងអត់ខ្វល់!

ក៖ អុំ....

ខ៖ ចាស!
អូនអើយយើងអត់ខ្វល់ថាអាញ់មានកូនធ្វើចោរយើងពីបាកហើយអញ្ចឹះមួយគេធ្វើបាបអញ្ចឹងបិបាកអីអត់មានទេឥឡូវយើងការអោយគេហើយខែពីររួចហើយអាមុននោះឥឡូវការបានដប់ឆ្នាំហើយ
ឥឡូវយាយតាយើងខំប្រឹងរកលុយសងគេទៅនិងវារួចហើងបើប្ដីចង់បានតុកតុកយើងសន្សំបាន (សើច)!

ក៖ អញ្ចឹងសប្បាយចិត្តហើយអុំ! (មានសំលេងរំខានពីខាងក្រៅ)

ខ៖ អឺ....

ក៖
អញ្ចឹងអុំអរគុណច្រើនជាចុងក្រោយអុំមានពាក្យពេចន៍អ្វីដើម្បីផ្ដាំផ្ញើរដល់អ្នកដែលបានស្ដាប់ជាពិសេសកូនរបស់អុំផ្ទាល់! (មានសំលេងរមខានពីខាងក្រៅ)

ខ៖
អានិងហើយយើងផ្ដាំផ្ញើរដូចថាអោយយើងខំប្រឹងគិតទៅរកស៊ីអីអោយដឹងរកនិងអញ្ចឹងទៅអោយសប្បាយៗអញ្ចឹងទៅកុំមកដើរផ្លូចខុសផ្លូវអីអញ្ចឹងណាអូនមិនថាកូនគេកូនយើងទេ
យើងខំប្រឹងប្រាប់ធ្វើអញ្ចឹងៗអត់ល្អធ្វើល្អអោយគេស្រលាញ់អញ្ចឹងទៅណាអូន ចាស!

ក៖ ចាស! អរគុណអុំ!

ខ៖ ចាស!